អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ៥២១ អាជ.១៧អអក

ភ្នំពេញ, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីនៅស្រុកជាំក្សាន្ត ស្រុកគូលេន និងនៅផ្នែកខ្លះស្រុកសង្គមថ្មី ខេត្តព្រះវិហារ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ លាភ ស្រីអ័ង សេវាករឈ្មោះ អ៊ូ គឹមសៀង សេវាករឈ្មោះ កែវ ងួន សេវាករឈ្មោះ ប៊ាន ឌីណា សេវាករឈ្មោះ តេង គឹមស្រៀង និងសេវាករឈ្មោះ កែវ សុវណ្ណនី

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនជា **អ្នកប្រើប្រាស់អគ្គិសនី** នៅស្រុកជាំក្សាន្ត ស្រុកគូលេន និងនៅផ្នែកខ្លះស្រុកសង្គមថ្មី ខេត្តព្រះវិហារ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករឈ្មោះ លាភ ស្រីអ័ង សេវាករឈ្មោះ អ៊ូ គឹមសៀង សេវាករឈ្មោះ កែវ ងួន សេវាករឈ្មោះ ប៊ាន ឌីណា សេវាករឈ្មោះ តេង គឹមស្រៀង និងសេវាករឈ្មោះ កែវ សុវណ្ណនី មេត្តាជ្រាបថា កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានព្រមព្រៀងអនុញ្ញាតឲ្យ**ក្រុមហ៊ុន ប៊ី.ធី.ស៊ី ផៅវ័រ ឌីវែឡុបមិន** ធ្វើការបញ្ជូនអគ្គិសនីបន្តតាមខ្សែបញ្ជូនរងពីព្រំដែនប្រទេសឡាវ នៅស្រុកឆែប មានចម្ងាយជាង ១០០ គីឡូម៉ែត្រ មកផ្គត់ផ្គង់លក់អគ្គិសនីដុំ ឲ្យសេវាករមួយចំនួននៅក្នុងខេត្តព្រះវិហារ ដើម្បីជំនួសអគ្គិសនីប្រើម៉ាស៊ីនដេរ៉ូសែលតូចៗ ដើម្បីបន្ថយអត្រាថ្លៃលក់ឲ្យថយចុះបានមួយចំនួនធំ និងបានបន្ថែមរយៈពេលផ្គត់ផ្គង់ សម្រួលដល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ ។ ក្នុងខែកញ្ញា ឆ្នាំ២០១៧ កន្លងមក អគ្គិសនីកម្ពុជាបានពង្រីកខ្សែបណ្តាញបញ្ជូនរង និងបានបញ្ជូនអគ្គិសនីប្រភពប្រទេសឡាវ ទៅដល់តំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករចំនួន ៦ ទៀត នៅស្រុកជាំក្សាន្ត ស្រុកគូលេន និងនៅផ្នែកខ្លះស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលកំពុងបានតភ្ជាប់ជាបន្តបន្ទាប់ ទន្ទឹមនឹងនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យគណនាថ្លៃដើមអគ្គិសនីឡើងវិញ តាមថ្លៃប្រភពអគ្គិសនីពីប្រទេសឡាវថ្មីនេះ ស្របតាមនីតិវិធីរបស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការវាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី រួចអាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងធ្វើការសម្រេចបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនី នៅតំបន់ផ្គត់ផ្គង់ទាំង ៦ **បញ្ចុះអត្រាថ្លៃលក់ប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូតជាង ២,០០០ រៀល មក ១,១០០ រៀល/គីឡូវ៉ាត់ម៉ោង អនុវត្តគិតពីពេលចេញវិក្កយបត្រថ្លៃអគ្គិសនីប្រើប្រាស់ ចាប់ពីចុងខែតុលា[1] ឆ្នាំ២០១៧ តទៅ** រហូតដល់ខ្សែបញ្ជូន តង់ស្យុងខ្ពស់បញ្ជូនប្រភពអគ្គិសនីពីប្រទេសឡាវ មកដល់អនុស្ថានីយជ័យសែន និងដាក់ឲ្យដំណើរការ ។

---

[1] អនុវត្តតំបន់ដែលបានភ្ជាប់រួច ៤ សេវាករ (សេវាករ លាភ ស្រីអ័ង, សេវាករ អ៊ូ គឹមសៀង, សេវាករ កែវ ងួន និងសេវាករ ប៊ាន ឌីណា) អនុវត្តក្រោយពេលភ្ជាប់ ១ ខែ តំបន់ដែលមិនទាន់ភ្ជាប់ចំនួន ២ សេវាករ (សេវាករ តេង គឹមស្រៀង និងសេវាករ កែវ សុវណ្ណនី)

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា សូមដាក់ "ឯកសារបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនី" នេះ ពិគ្រោះយោបល់ជាសាធារណៈជាមួយអ្នកពាក់ព័ន្ធទាំងអស់ មានក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់អ្នកផ្គត់ផ្គង់ទាំង ៦ នៅខេត្តព្រះវិហារ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ។ ក្រោយថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧** "ឯកសារបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនី" ថ្មីនេះ នឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការពិនិត្យ និងអនុម័តបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីថ្មីនេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា អាចអនុវត្តការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា សំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកផ្គត់ផ្គង់អគ្គិសនី ផង ។ ឯកសារបញ្ចុះថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ **អាជ្ញាធរអគ្គិសនីកម្ពុជា, សាលាខេត្តព្រះវិហារ, មន្ទីររ៉ែ និងថាមពល ខេត្តព្រះវិហារ, សាលាស្រុកជាំក្សាន្ត និងនៅសាលាស្រុកសង្គមថ្មី និងនៅតំបន់របស់អ្នកផ្គត់ផ្គង់ទាំង ៦** សម្រាប់អ្នកពាក់ព័ន្ធ ក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់ទាំងអស់ ដែលមានចំណាប់អារម្មណ៍ អាចពិនិត្យដោយសេរីនៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់មកអាជ្ញាធរអគ្គិសនីកម្ពុជា លើ "ឯកសារបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនី" នេះ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh